# ៣- សេចក្តីជូនដំណឹង

ភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

## សេចក្តីជូនដំណឹងលេខ : ៦២៩ សជណ.ពហ

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សូមជំរាបជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ**

**កម្មវត្ថុ :** ករណីសំណើសុំរាជានុញ្ញាត និងអនុញ្ញាតចរាចរក្រដាសប្រាក់ ៥០ រៀល ខ្នាតតូចឡើងវិញ

**យោង :**

- លិខិតលេខ ៥០៣ កបវ. ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៣ របស់ក្រសួងហិរញ្ញវត្ថុ
- មតិរបស់ឯកឧត្តម នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៣
- ព្រះរាជចំណាររបស់ស្តេចក្រុមហ្លួងនាយករដ្ឋមន្ត្រីទី ១ នៃរាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

ឆ្លើយតបសំណើដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំមានកិត្តិយសសូមជំរាបជូនឯកឧត្តមរដ្ឋមន្ត្រីថា: ព្រះអង្គស្តេចក្រុមហ្លួងនាយករដ្ឋមន្ត្រីទីមួយ និងឯកឧត្តមនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា បានយល់ព្រម ក្នុងដាក់អោយធ្វើចរាចរឡើងវិញនូវក្រដាសប្រាក់ ៥០ រៀលខ្នាតតូច និងអាចធ្វើការណែនាំចំពោះវិធានការអនុវត្តដូចខាងក្រោម :

- ធានាអោយបាននូវស្ថេរភាពតំលៃទំនិញជាទូទៅ ហើយនិងមាននិន្នាការថយចុះទៀតផង ។

- បញ្ជាអោយគ្រប់ស្ថាប័នរបស់រដ្ឋនិងមន្ត្រីរាជការទាំងអស់ ធ្វើជាគំរូក្នុងការទទួលទូទាត់ក្រដាសប្រាក់ប្រភេទនេះ និងរាប់ស្កាត់រាល់អំពើកេងបន្លំតាមវិធី ប្រមូលក្រដាសប្រាក់នេះដោយបន្ថយតំលៃ " កាត់ទឹក " យកមកដូរជាមួយធនាគារវិញ ។

- អប់រំប្រជារាស្ត្រអោយបានយល់ និងមានជំនឿលើក្រដាសប្រាក់នេះ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រីជ្រាប និងមានវិធានការអនុវត្តតាមន័យដូចបានជំរាបជូនខាងលើ អោយសំរេចបានលទ្ធផលល្អ តាមការគួរ ។

ជ.សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**នូច កានុន**

*********